# អនុក្រឹត្យលេខ ២៤ អនក្រ.បក
# ស្តីពី ការលុបថ្លៃឈ្នួលដែននេសាទ
# លើឧបករណ៍នេសាទសិប្បកម្មទឹកសាប

❋❋❋

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ. ចុះថ្ងៃទី ០៩ ខែ ឧសភា ឆាំ ១៩៨៩ ស្តីពីការជួលដែននេសាទទឹកសាបនឹងសមុទ្រអោយធ្វើអាជីវកម្ម
- បានឃើញប្រកាសរបស់ក្រសួងកសិកម្ម ០២៨ កសក. ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ ស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប និងសមុទ្រ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**១.-**

លុបការយកថ្លៃឈ្នួលដែននេសាទលើឧបករណ៍នេសាទសិប្បកម្មទឹកសាបគ្រប់ប្រភេទ ចាប់ពីពេលនេះតទៅ ។

**មាត្រា ២.-**

ឧបករណ៍នេសាទសិប្បកម្មគ្រប់ប្រភេទ ដែលបានកំណត់ក្នុងប្រកាសរបស់ក្រសួងកសិកម្ម លេខ ០២៨ កសក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ ស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាបនិងសមុទ្រ មិនត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទនៅក្នុងរដូវបិទនេសាទឡើយ ។

**មាត្រា ៣ .-**

អ្នកនេសាទគ្រប់រូប មិនត្រូវប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ និងប្រព្រឹត្តសកម្មភាពផ្ទុយនឹងច្បាប់ ឬ លិខិតបទដ្ឋាននានាដែលបានកំណត់រួចហើយនោះទេ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ២៥ អនក្រ.បក**

**ស្តីពីស្តីពីការបង្កើត**

**ស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា**

**ប្រចាំសាធារណរដ្ឋកូរ៉េ**

***

**រាជរដ្ឋាភិបាល**

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា